**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

**តុលាការរដ្ឋប្បវេណី**
-សំណុំរឿងរដ្ឋប្បវេណីលេខ ៥១១
ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣
-សាលក្រមរដ្ឋប្បវេណី
លេខ ០១ "ណ"/០៤
ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តសៀមរាប នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ វេលាព្រឹក។

**ចៅក្រម**

-លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប

-ដើមចោទៈ ឈ្មោះ [redacted] សុខុម ភេទស្រី ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩០ អាសយដ្ឋានបច្ចុប្បន្ន [redacted]។

អ្នកតំណាងដោយអាណត្តិ មេធាវី [redacted] អត្តលេខ ២៧០៣T ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវី នៃក្រុមមេធាវី [redacted] មានការិយាល័យនៅដីឡូតិ៍ [redacted]។

-ចុងចម្លើយៈ ឈ្មោះ [redacted] កែវ ភេទប្រុស ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨១ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted]។

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១.លែងលះពីចុងចម្លើយឈ្មោះ [redacted] កែវ។

២.ប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] គីតធើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឱ្យដើមចោទឈ្មោះ [redacted] សុខុម។

៣.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] កែវ ប្រគល់កូនឈ្មោះ [redacted] គីតធើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឱ្យដើមចោទ។

៤.ឱ្យចុងចម្លើយប្រគល់ម៉ូតូ ១គ្រឿង ម៉ាក Scopy សេរីឆ្នាំ២០១៩ ពណ៌ស ស្លាកលេខ សៀមរាប 1AD-8362 ឱ្យដើមចោទអ្នកគ្រប់គ្រងវិញ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

### ខ. ដំណើររឿងក្តី និងចំណុចវិវាទ

#### ខ.១. ការសង្ខេបអំពីរឿងក្តី

រឿងក្តីនេះ គឺជារឿងក្តីដែលដើមចោទឈ្មោះ [redacted] សុខុម និងចុងចម្លើយឈ្មោះ [redacted] កែវ បានរៀបការជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ៦៩

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ ក្នុងចំណងអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយ មានកូនចំនួន ១នាក់ ឈ្មោះ កែវ ភីតជើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។ ដើមចោទបានដាក់ពាក្យបណ្តឹង ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ លែងលះពីចុងចម្លើយ ដោយមូលហេតុ ចុងចម្លើយប្រើអំពើហិង្សា ជេរប្រមាថ ដើមចោទ ឪពុកម្តាយបងប្អូនដើមចោទ បង្ខូចកេរ៍ឈ្មោះដើមចោទ និងគម្រាមកំហែងថានឹងសម្លាប់ដើមចោទ ដែលធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ។

**ខ.២. អង្គហេតុដែលគ្មានវិវាទ**

ចំណុចដែលគ្មានវិវាទ: គ្មាន។

**ខ.៣. ចំណុចដែលមានវិវាទ**

១.តើដើមចោទសុំលែងលះពីចុងចម្លើយ មានមូលហេតុត្រឹមត្រូវដែរទេ?

២.តើការសុំសិទ្ធិអំណាចមេបាលើកូន ឈ្មោះ [redacted] ភីតជើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១ របស់ដើមចោទ មានមូលហេតុត្រឹមត្រូវដែរទេ?

៣.តើការសុំឱ្យចុងចម្លើយប្រគល់កូនឈ្មោះ [redacted] ភីតជើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១ របស់ដើមចោទ មានមូលហេតុត្រឹមត្រូវដែរទេ?

៤.តើការសុំឱ្យចុងចម្លើយ ប្រគល់ម៉ូតូ ១គ្រឿង ម៉ាក Scopy សេរីឆ្នាំ២០១៩ ពណ៌ស ស្លាកលេខ សៀមរាប 1AD-8362 ឱ្យមកដើមចោទវិញ មានមូលហេតុត្រឹមត្រូវដែរទេ?

**ខ.៤. ការអះអាងរបស់គូភាគី**

ខ.៤.១. ស្តីពីការទាមទារចំណុចទី ១

-ការអះអាងរបស់ភាគីដើមចោទ

ដើមចោទឈ្មោះ [redacted] សុខុម បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារលែងលះពីចុងចម្លើយឈ្មោះ [redacted] កែវ ដោយមូលហេតុ ចុងចម្លើយប្រើអំពើហិង្សាមកលើខ្លួន មិនតែប៉ុណ្ណោះចុងចម្លើយក៏បានជេរប្រមាថខ្លួន ឪពុក ម្តាយ និងបងប្អូនរបស់ខ្លួន គឺខ្លួនបានរងសម្ពាធយ៉ាងខ្លាំងក្នុងការរស់នៅជាមួយចុងចម្លើយ ជាងនេះទៅទៀតចុងចម្លើយបានបង្ហោះសារ បង្ខូចកេរ៍ឈ្មោះខ្លួន។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ ខាងសង្កាត់ក៏បានហៅខ្លួន និងចុងចម្លើយ សម្របសម្រួលឱ្យធ្វើកិច្ចសន្យាទាំងពីរនាក់ ឱ្យបញ្ឈប់ទាក់ទងនឹងការជេរប្រមាថតាមប្រព័ន្ធសង្គមហ្វេសបុក ប៉ុន្តែក្រោយមកទៀត ចុងចម្លើយមិនគោរពតាមកិច្ចសន្យានោះទេ ខ្លួនខ្លាច ខ្លួនបារម្ភ មិនហ៊ានរួមរស់នៅជាមួយចុងចម្លើយ ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយ។ ខ្លួន និងចុងចម្លើយបានបែកលំនៅពីគ្នា តាំងពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ដោយខ្លួនជាអ្នកចុះចេញពីផ្ទះ។

-ការអះអាងរបស់ភាគីចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] កែវ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសុំប្រានចោលនូវការទាមទារលែងលះ ដោយមូលហេតុ ខ្លួនស្រឡាញ់កូន នៅស្រឡាញ់ដើមចោទ តែដើមចោទ បងប្អូនដើមចោទ បិទសិទ្ធិមិនឱ្យខ្លួនចូលផ្ទះជួបនិយាយជាមួយដើមចោទ ខ្លួនពុំមានវិធីចូលទៅជិតដើមចោទបាន។ ដើមចោទដាក់ពាក្យបណ្តឹង ដោយមានមិត្តភក្តិ បងប្អូន នៅពីក្រោយ បញ្ជោះឱ្យដើមចោទលែងលះខ្លួន ដោយចោទប្រកាន់លើខ្លួន គឺខ្លួនមិនប្រើអំពើហិង្សាលើដើមចោទ មិនបានជេរប្រមាថដើមចោទ។ ឯការជេរប្រមាថ ឪពុកម្តាយ និងបងប្អូនរបស់ដើមចោទ ខ្លួនជេរប្រាកដមែន ប៉ុន្តែដោយសារតែដើមចោទ បានជេរប្រមាថ ឪពុកម្តាយ និងបងប្អូនរបស់ខ្លួនដែរ គឺមានជេរទៅជេរមកលើបណ្តាញសង្គមហ្វេសបុក។ ក្រោយមានកិច្ចសន្យាបញ្ឈប់នៅអាជ្ញាធរ



Scanned with CamScanner

គឺខ្លួនគោរពតាមកិច្ចសន្យា មិនដូចដើមចោទបានថ្លែងអះអាងខាងលើនោះទេ។ ខ្លួន និងដើមចោទ ពិតជាបានបែកលំនៅពីគ្នា តាំងពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ដោយដើមចោទជាអ្នកចុះចេញពីផ្ទះ។

ខ.៤.២. ស្តីពីការទាមទារចំណុចទី ២

-ការអះអាងរបស់ភាគីដើមចោទ

ដើមចោទឈ្មោះ [redacted] សុខុម បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ភីតធើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ សុំឱ្យតុលាការសម្រេចចុះ បើតាមចិត្តរបស់ខ្លួន ខ្លួននៅក្បាសុំដដែល ដោយមូលហេតុ ខ្លួនមានការងារធ្វើ មានលទ្ធភាព មានចំណូលក្នុងមួយខែចំនួន ៤០០ (បួនរយ) ដុល្លារអាមេរិក ដែលអាចមានលទ្ធភាពចិញ្ចឹមកូនបាន មានទីលំនៅសមរម្យ ដោយរស់ជាមួយឪពុកម្តាយខ្លួន ដែលមានឪពុកម្តាយខ្លួនជាអ្នកជួយមើលថែកូនឱ្យ។ បើប្រគល់កូនឱ្យរស់នៅជាមួយចុងចម្លើយ ក៏ចុងចម្លើយនឹងយកកូនទៅឱ្យម្តាយរបស់គាត់ជួយមើលថែឱ្យដដែល ហើយម្តាយរបស់ចុងចម្លើយក៏មានវ័យចាស់ជរា មិនអាចមើលថែកូនរបស់ខ្លួនបានល្អនោះទេ ពេលនេះកូននៅនឹងចុងចម្លើយមើលថែចិញ្ចឹម។

-ការអះអាងរបស់ភាគីចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] កែវ បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ភីតធើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ខ្លួនមិនឯកភាពប្រគល់កូនឱ្យទៅដើមចោទទេ ខ្លួនសុំឱ្យតុលាការសម្រេចប្រគល់កូនឱ្យខ្លួនមើលថែចិញ្ចឹមវិញ ដោយសារបច្ចុប្បន្នកូននៅនឹងខ្លួនមើលថែចិញ្ចឹមស្រេច ដើមចោទមិនស្រឡាញ់កូន សូម្បីតែកូនដើមរបស់ដើមចោទជាមួយប្តីមុន ក៏ដើមចោទយកកូននោះ ទៅដាក់ឱ្យរស់នៅកន្លែងកុមារកំព្រា នៅឯខេត្តកំពង់ចាមដែរ ឯឪពុកម្តាយក្មេករបស់ខ្លួនដែលជាតាយាយរបស់កូនខ្លួននេះ ក៏មិនស្រឡាញ់ចៅដែរ ព្រោះពេលចៅឈឺ តាយាយក៏ពុំដែលសួរនាំដែរ ទាំងតាយាយ និងដើមចោទ មិនមានផ្ទះរស់នៅច្បាស់លាស់នោះទេ ព្រោះផ្ទះដែលកំពុងរស់នៅរាល់ថ្ងៃ ជាផ្ទះរបស់កូនស្រីម្តាយក្មេក ដែលត្រូវជាបងស្រីរបស់ដើមចោទដែលនៅសហរដ្ឋអាមេរិក។ ខ្លួនសុំសិទ្ធិអំណាចមេបាលើកូន គឺខ្លួនចិញ្ចឹមកូននេះបានល្អជាងដើមចោទ ខ្លួនអាចផ្តល់ភាពកក់ក្តៅឱ្យកូនបាន មិនចង់ឱ្យកូនកំព្រាឪពុកទៀតទេ ខ្លួនមានលទ្ធភាពចិញ្ចឹមកូនបាន មានមុខរបរទិញលក់ឡាន មានចំណូលក្នុងមួយខែជាមធ្យមអាចបានចំនួន ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិក ដែរ ខ្លួនមានផ្ទះផ្ទាល់ខ្លួនអាចឱ្យកូនរស់នៅបាន ពេលខ្លួនមានការរវល់ចេញទៅក្រៅម្តងម្កាល ខ្លួនអាចយកកូនផ្ញើនឹងម្តាយរបស់ខ្លួនឱ្យមើលថែបាន ម្តាយរបស់ខ្លួនមានកម្លាំងមាំមួនសុខភាពល្អ គាត់នៅតែផ្ទះ មើលថែកូនរបស់ខ្លួនឱ្យបាន។ កន្លងមកកូនរបស់ខ្លួនឈឺ គឺបានម្តាយរបស់ខ្លួនជួយមើលថែឱ្យដែរ។

ខ.៤.៣. ស្តីពីការទាមទារចំណុចទី ៣

-ការអះអាងរបស់ភាគីដើមចោទ

ដើមចោទឈ្មោះ [redacted] សុខុម បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] កែវ ប្រគល់កូនឈ្មោះ [redacted] ភីតធើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឱ្យមកខ្លួន ដោយសារ បច្ចុប្បន្នកូនឈ្មោះ [redacted] ភីតធើរ រស់នៅជាមួយចុងចម្លើយ ហើយពេលនេះចុងចម្លើយបានឱ្យម្តាយរបស់គាត់ជួយមើលថែ។

-ការអះអាងរបស់ភាគីចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] កែវ បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារឱ្យប្រគល់កូនឱ្យដើមចោទ ខ្លួនមិនឯកភាពនោះទេ។ បច្ចុប្បន្នកូនឈ្មោះ [redacted] ភីតធើរ រស់នៅជាមួយខ្លួនប្រាកដមែន ប៉ុន្តែ ខ្លួនមិនឯកភាព

ក្នុងការប្រគល់កូនឱ្យទៅដើមចោទនោះ ដោយសារតែខ្លួនក៏សុំសិទ្ធិអំណាចមេបាលើកូននេះផងដែរ ម្យ៉ាងទៀត ខ្លួនអាចចិញ្ចឹមកូននេះបានល្អជាងដើមចោទ។

ខ.៤.៤. ស្តីពីការទាមទារចំណុចទី ៤

-ការអះអាងរបស់ភាគីដើមចោទ

ដើមចោទឈ្មោះ [redacted] សុខុម បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារឱ្យចុងចម្លើយប្រគល់ម៉ូតូ ១ គ្រឿង ម៉ាក Scopy សេរីឆ្នាំ២០១៩ ពណ៌ស ស្លាកលេខ សៀមរាប 1AD-8362 ដោយមូលហេតុ ម៉ូតូនេះ ខ្លួនបានទិញបង់រំលស់ ទិញតាំងពីឆ្នាំ២០១៨ ដែលមានមុនពេលខ្លួនរៀបអាពាហ៍ពិពាហ៍ ដូចមានបញ្ជាក់ក្នុងបណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១៨ និងឯកសារបង់រំលស់ផងដែរ។ បច្ចុប្បន្ន ម៉ូតូនេះនៅចុងចម្លើយកាន់កាប់ ចំណែកប័ណ្ណសម្គាល់យានយន្តនៅកន្លែងបញ្ចាំ ហើយខ្លួនជាអ្នកបង់ប្រាក់ឱ្យហាងបញ្ចាំ និងបានបង់រំលស់ជារៀងរាល់ខែ ទើបខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យចុងចម្លើយប្រគល់ម៉ូតូខាងលើនេះ ឱ្យមកខ្លួនវិញ។

-ការអះអាងរបស់ភាគីចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] កែវ បានធ្វើសេចក្តីថ្លែងការណ៍ថា ការទាមទារឱ្យប្រគល់ម៉ូតូ ១គ្រឿង ម៉ាក Scopy សេរីឆ្នាំ២០១៩ ពណ៌ស ស្លាកលេខ សៀមរាប 1AD-8362 ខ្លួនមិនអាចប្រគល់ម៉ូតូនេះឱ្យដើមចោទបានទេ ព្រោះម៉ូតូនេះត្រូវបានម្ចាស់បំណុលមកទាមទារបំណុល ពេលម្ចាស់បំណុលមកទាមទារប្រាក់ ខ្លួនអត់មានប្រាក់សង ខ្លួនក៏បានឱ្យម្ចាស់បំណុលដកយកម៉ូតូនេះទៅបាត់ហើយ។ ខ្លួន និងដើមចោទខ្ចីបំណុលរួមគ្នាមានជំពាក់ធនាគារផង ជំពាក់ឯកជនផង បានយកម៉ូតូ១គ្រឿង និងរថយន្ត១គ្រឿង របស់ខ្លួនទៅដាក់បញ្ចាំ។ បើចង់បានម៉ូតូ ត្រូវមានប្រាក់ចំនួន ៤.៣០០ (បួនពាន់បីរយ) ដុល្លារអាមេរិក ទៅលោះយកម៉ូតូនេះវិញបាន។

ខ.៤.៥. ស្តីពីការទាមទារចំណុចទី ៥

-ការអះអាងរបស់ភាគីដើមចោទ

ដើមចោទឈ្មោះ [redacted] សុខុម បានធ្វើសេចក្តីថ្លែងការណ៍ថា ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ដោយសារចុងចម្លើយជាអ្នកមានកំហុសក្នុងរឿងនេះ។

-ការអះអាងរបស់ភាគីចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] កែវ បានធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះប្រាក់ប្រដាប់ក្តីសុំឱ្យដើមចោទជាអ្នកទទួលបន្ទុក ព្រោះដើមចោទជាអ្នកប្តឹងខ្លួន។

## ការពិនិត្យភស្តុតាង

**ភស្តុតាងជាឯកសាររបស់ដើមចោទ ៖**

១-សំបុត្រអាពាហ៍ពិពាហ៍លេខ ៦៩ សៀវភៅអាពាហ៍ពិពាហ៍លេខ ០២/២០២១ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ (ថតចម្លង)

២-សំបុត្រកំណើតលេខ ៧៤ សៀវភៅបញ្ជាក់កំណើតលេខ ០១/២០១០ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប របស់ឈ្មោះ [redacted] សុខុម។ (ថតចម្លង)

៣-សំបុត្របញ្ជាក់កំណើតលេខ ៤០ សៀវភៅបញ្ជាក់កំណើតលេខ ០១/២០០៩ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ របស់ឈ្មោះ [redacted] កែវ។ (ថតចម្លង)



Scanned with CamScanner

៤-សំបុត្របញ្ជាក់កំណើតលេខ ៨៤ សៀវភៅបញ្ជាក់កំណើតលេខ ០១/២០២២ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប របស់ឈ្មោះ [redacted]កីតធើរ។ (ថតចម្លង)

៥-សៀវភៅគ្រួសារ ។ (ថតចម្លង)

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

**១.ស្តីអំពី ការទាមទារលែងលះ**

១.១.តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៦៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ព្រមទាំងការអះអាងរបស់ដើមចោទ ដែលបានអះអាងថា ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដូចមាននៅក្នុងសំបុត្រអាពាហ៍ពិពាហ៍លេខ ៦៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ នោះ គឺអាចឱ្យតុលាការជឿបានថា ដើមចោទ និងចុងចម្លើយ ពិតជាបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ពិតប្រាកដមែន។ ការដែលដើមចោទ និងចុងចម្លើយ រស់នៅជាមួយគ្នា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាបែបនេះ គឺមានន័យថាដើមចោទ និងចុងចម្លើយ មានជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា គឺរស់នៅជាមួយគ្នាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

១.២.ដើមចោទបានអះអាងថា ខ្លួនសុំលែងលះជាមួយចុងចម្លើយ ដោយមូលហេតុ ចុងចម្លើយប្រើអំពើហិង្សាមកលើខ្លួន ជេរប្រមាថខ្លួន ឪពុកម្តាយ និងបងប្អូនរបស់ខ្លួន និងបានបង្ហោះសារបង្ខូចកេរ៍ឈ្មោះខ្លួន ដែលធ្វើឱ្យខ្លួនរងសម្ពាធយ៉ាងខ្លាំងក្នុងការរស់នៅជាមួយចុងចម្លើយ។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ ខាងសង្កាត់ក៏បានហៅខ្លួន និងចុងចម្លើយ សម្របសម្រួលឱ្យធ្វើកិច្ចសន្យាទាំងពីរនាក់ ឱ្យបញ្ឈប់ទាក់ទងនឹងការជេរប្រមាថ តាមប្រព័ន្ធសង្គមហ្វេសបុក ប៉ុន្តែក្រោយមកទៀត ចុងចម្លើយមិនគោរពតាមកិច្ចសន្យានោះទេ។ ខ្លួនខ្លាច ខ្លួនបារម្ភ មិនហ៊ានរួមរស់នៅជាមួយចុងចម្លើយ ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយ និងបានបែកលំនៅពីគ្នា តាំងពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន។ ប៉ុន្តែ ចុងចម្លើយបានអះអាងថា ខ្លួនសុំប្រានចោលនូវការទាមទារលែងលះ ព្រោះខ្លួនស្រឡាញ់កូន នៅស្រឡាញ់ដើមចោទ។ ដើមចោទដាក់ពាក្យបណ្តឹង ដោយមានមិត្តភក្តិ បងប្អូន នៅពីក្រោយ បញ្ចេះឱ្យដើមចោទលែងលះខ្លួន ដោយចោទប្រកាន់លើខ្លួន គឺខ្លួនមិនប្រើអំពើហិង្សា និងបានជេរប្រមាថដើមចោទទេ។ ឯការជេរប្រមាថ ឪពុកម្តាយ និងបងប្អូនរបស់ដើមចោទ ខ្លួនជេរប្រាកដមែន ប៉ុន្តែ ដោយសារតែដើមចោទ បានជេរប្រមាថ ឪពុកម្តាយ និងបងប្អូនរបស់ខ្លួនដែរ គឺមានជេរទៅជេរមកលើបណ្តាញសង្គមហ្វេសបុក។ ក្រោយមានកិច្ចសន្យាបញ្ឈប់នៅអាជ្ញាធរ គឺខ្លួនគោរពតាមកិច្ចសន្យា មិនដូចដើមចោទបានថ្លែងអះអាងខាងលើនោះទេ។ ខ្លួន និងដើមចោទ ពិតជាបានបែកលំនៅពីគ្នា តាំងពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ប្រាកដមែន។ ទោះបីជា ចុងចម្លើយពុំឯកភាពក្នុងការលែងលះពីដើមចោទក៏ដោយ ប៉ុន្តែ ផ្អែកតាមការអះអាងរបស់ដើមចោទ និងតាមការអះអាងរបស់ចុងចម្លើយខាងលើនេះ គឺធ្វើឱ្យតុលាការជឿថា ចំណងអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយ ពិតជាត្រូវបានបែកបាក់ ដោយគ្មានសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាននោះទេ។

១.៣.ការដែលចំណងអាពាហ៍ពិពាហ៍ រវាងដើមចោទ និងចុងចម្លើយ ត្រូវបានបែកបាក់ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាននោះ គឺបង្ហាញឱ្យឃើញថា ការទាមទារលែងលះរបស់ដើមចោទ

គឺស្របតាមចំណុច ង កថាខណ្ឌទី ១ មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយ លែងលះគ្នា តាមការស្នើសុំរបស់ដើមចោទ។

២.ស្តីអំពី ការសុំសិទ្ធិអំណាចមេបាលើកូន

២.១.តាមសំបុត្របញ្ជាក់កំណើតកូន ឈ្មោះ [redacted] ភីតជើរ លេខ ៨៤ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប និងតាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ដែលបានអះអាងដូចគ្នាថា ក្នុងចំណងអាពាហ៍ពិពាហ៍ពួកខ្លួនមានកូនប្រុសម្នាក់ឈ្មោះ [redacted] ភីតជើរ កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ នោះ គឺអាចឱ្យតុលាការជឿបានថា ក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយ ពិតជាមានកូនប្រុសម្នាក់ឈ្មោះ [redacted] ភីតជើរ កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ប្រាកដមែន។

២.២.ដើមចោទ និងចុងចម្លើយ ពុំបានព្រមព្រៀងគ្នាក្នុងការកំណត់យកអ្នកដែលមានអំណាចមេបាលើកូននោះទេ ដោយបានទាមទារអំណាចមេបាលើកូនរៀងៗខ្លួន។ ប៉ុន្តែ ផ្អែកតាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ដែលបានអះអាងដូចគ្នាថា ពួកគេបានបែកលំនៅពីគ្នា ដោយដើមចោទជាអ្នកចុះចេញពីផ្ទះតាំងពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ហើយកូនប្រុសរបស់ពួកគេ គឺរស់នៅជាមួយចុងចម្លើយរហូតមកដល់បច្ចុប្បន្ន។ ម្យ៉ាងទៀត តាមការអះអាងរបស់ចុងចម្លើយ ឃើញថា ចុងចម្លើយមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន ដោយចុងចម្លើយមានមុខរបរទិញលក់ឡាន បានប្រាក់ចំណូលជាមធ្យម ៦០០ (ប្រាំមួយរយ) ដុល្លារអាមេរិក ក្នុង១ខែ និងមានផ្ទះផ្ទាល់ខ្លួនរស់នៅ ហើយពេលមានការរវល់ចុងចម្លើយមានម្តាយ ដែលអាចយកកូនទៅផ្ញើឱ្យជួយមើលថែបាន។ ឃើញថា ដោយកូនរបស់ដើមចោទ និងចុងចម្លើយ បានរស់នៅស្ថិតក្រោមការចិញ្ចឹមបីបាច់ថែរក្សារបស់ចុងចម្លើយ និងម្តាយចុងចម្លើយ តាំងពីចុងចម្លើយចុះចេញពីផ្ទះ កាលពីខែតុលា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ដែលនេះបង្ហាញឱ្យឃើញថា ចុងចម្លើយជាឪពុកអាចចិញ្ចឹមបីបាច់ថែរក្សាកូនបាន ទោះបីជាកូននៅតូចក៏ដោយ ហើយចុងចម្លើយក៏មានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមកូនបាន ណាមួយកូនរបស់ពួកគេជាកូនប្រុសផង។ បើប្រគល់កូនឱ្យទៅដើមចោទ ដែលពុំមានផ្ទះរស់នៅផ្ទាល់ខ្លួន និងមានប្រាក់ចំណូល ៤០០ (បួនរយ) ដុល្លារអាមេរិក ក្នុង១ខែ តិចជាងប្រាក់ចំណូលរបស់ចុងចម្លើយផងនោះ ពិតជាមិនអាចចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អនោះទេ។ ដូច្នេះ តុលាការមានជំនឿថា ចុងចម្លើយជាឪពុកអាចមានលទ្ធភាពចិញ្ចឹមបីបាច់ថែរក្សាកូន បានល្អជាងដើមចោទជាម្តាយ ដែលតុលាការគប្បីសម្រេចប្រគល់អំណាចមេបាលើកូនប្រុសឈ្មោះ [redacted] ភីតជ័រ ឱ្យទៅភាគីចុងចម្លើយ ស្របតាមកថាខណ្ឌទី ៣ មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

២.៣.ដើម្បីផលប្រយោជន៍កូន គប្បីអនុញ្ញាតឱ្យភាគីម្តាយដែលពុំមានអំណាចមេបាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីឪពុកដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្តាយក្នុងការទៅសួរសុខទុក្ខកូន។

៣.ស្តីអំពី ការសុំឱ្យចុងចម្លើយប្រគល់កូន

ដើមចោទឈ្មោះ [redacted] សុខុម បានទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] កែវ ប្រគល់កូនឈ្មោះ [redacted] ភីតជើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឱ្យមកខ្លួន ដោយសារបច្ចុប្បន្ន កូនរស់នៅជាមួយចុងចម្លើយ។ ប៉ុន្តែ ផ្អែកតាមសំអាងហេតុត្រង់ចំណុចទី ២ ខាងលើនេះ ឃើញថា តុលាការសម្រេចប្រគល់អំណាចមេបាលើកូនរបស់ដើមចោទ និងចុងចម្លើយ ឱ្យទៅចុងចម្លើយ។ ដូច្នេះ តុលាការគប្បីច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ។



Scanned with CamScanner

៤.ស្តីអំពី ការសុំឱ្យចុងចម្លើយប្រគល់ម៉ូតូ

៤.១.ដើមចោទបានអះអាង ខ្លួនសុំទាមទារឱ្យចុងចម្លើយប្រគល់ម៉ូតូ ១ គ្រឿង ម៉ាក Scopy សេរីឆ្នាំ ២០១៩ ពណ៌ស ស្លាកលេខ សៀមរាប 1AD-8362 ដោយមូលហេតុ ម៉ូតូនេះ ខ្លួនបានទិញបង់រំលស់ តាំងពីឆ្នាំ២០១៨ ដែលមានមុនពេលខ្លួនរៀបអាពាហ៍ពិពាហ៍ ហើយបច្ចុប្បន្ន ម៉ូតូនេះនៅចុងចម្លើយកាន់កាប់ ចំណែកប័ណ្ណសម្គាល់យានយន្តនៅកន្លែងបញ្ចាំ។ ប៉ុន្តែ ចុងចម្លើយបានអះអាង ខ្លួនមិនអាចប្រគល់ម៉ូតូនេះឱ្យដើមចោទបានទេ ព្រោះម៉ូតូនេះត្រូវបានម្ចាស់បំណុលមកទាមទារបំណុល ខ្លួនអត់មានប្រាក់សង ខ្លួនក៏បានឱ្យម្ចាស់បំណុលដកយកម៉ូតូនេះទៅបាត់ហើយ។

៤.២.តាមការអះអាងរបស់ចុងចម្លើយ ឃើញថា ម៉ូតូ ១ គ្រឿង ម៉ាក Scopy សេរីឆ្នាំ២០១៩ ពណ៌ស ស្លាកលេខ សៀមរាប 1AD-8362 នេះ មិនស្ថិតនៅក្រោមការកាន់កាប់របស់ចុងចម្លើយនោះទេ។ ម្យ៉ាងទៀត ដើមចោទក៏ពុំមានភស្តុតាង ដើម្បីបញ្ជាក់ឱ្យតុលាការជឿបានថា ម៉ូតូដែលដើមចោទទាមទារនេះ កំពុងស្ថិតនៅក្រោមការកាន់កាប់របស់ចុងចម្លើយនោះទេ។ ដូច្នេះ តុលាការគប្បីច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ។

៥-ស្តីអំពី បន្ទុកនៃប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តតាមកថាខណ្ឌទី១ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយឱ្យចុងចម្លើយឈ្មោះ [redacted]កែវ ជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១-លែងលះ ដើមចោទឈ្មោះ [redacted] សុខុម និងចុងចម្លើយឈ្មោះ [redacted] កែវ។

២-កំណត់ថា ចុងចម្លើយឈ្មោះ [redacted] កែវ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ភីតជើរ ភេទប្រុស កើតថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

ភាគីម្តាយដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីឪពុកដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្តាយ ក្នុងការទៅសួរសុខទុក្ខកូន។

៣-ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចទី២ ទី៣ និងទី៤។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ ២០២៤។ ក្នុងករណីភាគីមិនសុខចិត្តនឹងសាលក្រមនេះ អាចប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

សៀមរាប, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]